មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍

សើស្បែក និងកាមរោគ

# សិក្ខាសាលាថ្នាក់តំបន់ ស្តីពី « ការពិនិត្យមើលលទ្ធផល និងការស្វែករកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥ »



មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គសិក្ខាសាលាថ្នាក់តំបន់ស្តីពី **« ការពិនិត្យមើលលទ្ធផល និងការស្វែករកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥ »** ដែលប្រព្រឹត្តនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៥ នៅមន្ទីរអប់រំខេត្តព្រះសីហនុដោយមានការគាំទ្រថវិកា និងបច្ចេកទេសដោយគម្រោង US-CDC Cambodia ។ គោលបំណងនៃសិក្ខាសាលានេះគឺដើម្បីជានានូវលទ្ធផល និងសមមាត្រខ្ពស់នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ចុះឈ្មោះ ទទួលសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព ។ សិក្ខាសាលានេះក្រោមអធិបតី **លោកវេជ្ជ. ង៉ូវ ប៉ូរ៉ា** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង**លោក សែជូ សិទ្ធិជោតិ** អនុប្រធានមន្ទីរសុខាភិបាលខេត្តព្រះសីហនុដែលបានផ្តល់មតិណែនាំសំណាល និងប្រកាសបើកអង្គសិក្ខាសាលា។





វគ្គសិក្ខាសាលានេះមានការចូលរួមពីផ្នែកជំនាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគដូចជាផ្នែក AIDS Care ផ្នែក BCC ផ្នែក STI និងផ្នែក VCCT ផ្នែក LAB គ្លីនិក NCHADS និងមានការចូលរួមពី ប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុម ART និងអង្គការដៃគូ ដូចជា AHF CPN+ CWPD និង MHC សរុបចំនួន ៥៥ នាក់។ សិក្ខាសាលាមានការធ្វើបទបង្ហាញពីលទ្ធផលដែលសម្រេចបានទៅតាមសូចនាករនៃ ៩៥.៩៥.៩៥ និងកំណត់បញ្ហាអាទិភាព មូលហេតុដែលទាក់ទងនឹងលទ្ធផលនៃសូចនាករទាប និងរៀបចំផែនការសកម្មភាពដើម្បីកែលម្អរផងដែរ។